# សេចក្តីប្រកាសៈ «កម្មវិធីអាហារូបករណ៍សិល្បៈអមតៈ អាន ចនផន ឆ្នាំ២០២៥-២០២៦»

## «កម្មវិធីបណ្តុះបណ្តាលនិងអភិវឌ្ឍន៍»

| | |
|---|---|
| **ព័ត៌មានសំខាន់ៗ** | |
| **ឱកាស** | «អាហារូបករណ៍ និង ការបណ្តុះបណ្តាល» |
| **រចនាឡើងសម្រាប់** | «សិស្សនិស្សិតសិល្បៈ សិល្បករ និងអ្នកនៅក្នុងវិស័យសិល្បៈវប្បធម៌ដែលត្រូវការការបណ្តុះបណ្តាលបន្ថែម» |
| **នៅ** | «ក្នុងប្រទេសកម្ពុជា» |
| **អ្នកជាប់ថ្មីសរុប** | «ចំនួន ១០ នាក់ ដែលយ៉ាងហោចណាស់ ៥ នាក់ ផ្តល់ឱ្យនារី» |
| **រចនាសម្ព័ន្ធ និងពេលវេលាអនុវត្ត** | «ការសិក្សាជំនាញដែលបានស្នើសុំអាហារូបករណ៍នៅសាលាឬគ្រូឯកជន »<br>«ជំនួបសំណេះសំណាលពីវឌ្ឍនភាពការសិក្សាជាមួយអ្នកគ្រប់គ្រងកម្មវិធី»<br>«ការចូលរួមសិក្ខាវគ្គបណ្តុះគុណតម្លៃ» |
| **កាលបរិច្ឆេទសំខាន់ៗ** | «បេក្ខជន នឹងត្រូវចូលរួមកម្មវិធីតាមកាលបរិច្ឆេទដែលចេញផ្សាយក្នុងឯកសារ “ទិដ្ឋភាពទូទៅនៃកម្មវិធី” នៅចំណុចទី៧» |
| **ភាសាប្រើសម្រាប់ទំនាក់ទំនង** | «ភាសាខ្មែរ» |
| **ជំនួយគាំទ្រ** | «១,៥០០ ដុល្លារ ក្នុង១ឆ្នាំ» |
| **ថ្ងៃផុតទទួលពាក្យ** | «៣១ ឧសភា ២០២៥» |

## ព័ត៌មានកម្មវិធីៈ

កម្មវិធីនេះមានគោលដៅ ជួយគាំទ្រដល់អ្នកនៅក្នុងវិស័យសិល្បៈវប្បធម៌ដែលត្រូវការឱកាសនេះ អាចសិក្សានិងបញ្ចប់ការសិក្សាជំនាញសិល្បៈវប្បធម៌បានដោយជោគជ័យ អភិវឌ្ឍគុណតម្លៃផ្ទាល់ខ្លួនដែលមានការគិតទូលំទូលាយ និងបណ្តុះសក្តានុពលលើការដឹកនាំក្នុងវិស័យសិល្បៈវប្បធម៌។

ជ័យលាភីថ្មីសរុប ១០ នាក់ នឹងត្រូវបានជ្រើសរើស ដើម្បីចូលរួមនៅក្នុងកម្មវិធី ដែលនឹងកើតឡើងរយៈពេល ១២ ខែ ចាប់ពី ខែតុលា ឆ្នាំ២០២៥ ដល់ ខែកញ្ញា ឆ្នាំ២០២៦ ហើយនឹងបន្តទៅឆ្នាំបន្ទាប់ប្រសិនបើទទួលបានអាហារូបករណ៍លើសពីមួយឆ្នាំ។

បន្ទាប់ពីជាប់ជ័យលាភី អ្នកទទួលបានអាហារូបករណ៍នឹងចូលរៀនជំនាញដែលបានស្នើសុំអាហារូបករណ៍ ដែលកាលវិភាគរៀនអាស្រ័យលើស្ថាប័នបង្រៀនឬការព្រមព្រៀងជាមួយគ្រូឯកជន។ អ្នកទទួលបានអាហារូបករណ៍នឹងចូលរួមជំនួបសំណេះសំណាលជាមួយអ្នកគ្រប់គ្រងកម្មវិធី ស្តីពីវឌ្ឍនភាពការសិក្សានិងការប្រឹក្សាយោបល់ផ្សេងៗ ដែលកើតឡើងរៀងរាល់៦សប្តាហ៍ ម្តង។ ស្របពេលនេះដែរ អ្នកទទួលបានអាហារូបករណ៍ក៏តម្រូវឱ្យចូលរួមវគ្គបណ្តុះគុណតម្លៃ ទៅតាមកាលវិភាគដែលបានផ្តល់ជូនដោយសិល្បៈខ្មែរអមតៈ។

កម្មវិធីនេះសម្របសម្រួលដោយ លោក ឥន្ទ សម៉ាណាក់ ជាអ្នកគ្រប់គ្រងកម្មវិធីបណ្តុះបណ្តាលនិងអភិវឌ្ឍន៍ និងបណ្តុះបណ្តាលក្នុងវគ្គបណ្តុះគុណតម្លៃឆ្នាំទី១ដោយ លោកស្រី ឃុត សុចំប៉ាវឌ្ឍន៍ ដែលជាស្ថាបនិកស្ថាប័នទស្សនៈ។

ព័ត៌មានលម្អិតបន្ថែមស្តីពីចំណុចខាងក្រោម អាចរកបាននៅក្នុងឯកសារ «ទិដ្ឋភាពទូទៅនៃកម្មវិធី»៖

១. ប្រតិបត្តិការនៃកម្មវិធី
២. គោលដៅរបស់កម្មវិធី
៣. អត្ថប្រយោជន៍របស់កម្មវិធី
៤. អ្នកអាចដាក់ពាក្យក្នុងកម្មវិធី
៥. លក្ខខណ្ឌជ្រើសរើស
៦. ដំណើរការនៃការជ្រើសរើស
៧. រចនាសម្ព័ន្ធនិងពេលវេលាអនុវត្ត
៨. ក្រុមពាក់ព័ន្ធនឹងកម្មវិធី
៩. កាលបរិច្ឆេទសំខាន់ៗ

## លក្ខណសម្បត្តិត្រូវការ៖

ដើម្បីអាចចូលរួមកម្មវិធីបាន បេក្ខជនត្រូវ៖

- មានអាយុយ៉ាងតិច១៨ឆ្នាំ
- ជាពលរដ្ឋកម្ពុជា និងកំពុងរស់នៅក្នុងប្រទេសកម្ពុជា
- រៀនជំនាញសិល្បៈវប្បធម៌ណាមួយយ៉ាងតិច ៣ ឆ្នាំ ឬ ធ្វើការក្នុងវិស័យសិល្បៈវប្បធម៌យ៉ាងតិច ៣ ឆ្នាំ
- មានគោលបំណងនិងឆន្ទៈអភិវឌ្ឍជំនាញសិល្បៈនិងអាជីពរបស់ខ្លួននៅក្នុងវិស័យសិល្បៈវប្បធម៌ឱ្យឈានទៅរកកម្រិតអាជីព
- មានពេលគ្រប់គ្រាន់ចូលរួមកម្មវិធីតាមកាលបរិច្ឆេទទាំងអស់ដែលបានកំណត់

* *សូមមើលឯកសារ «ទិដ្ឋភាពទូទៅនៃកម្មវិធី» សម្រាប់ព័ត៌មានលម្អិតបន្ថែម។*

## របៀបដាក់ពាក្យ៖

សូមបំពេញព័ត៌មានរបស់អ្នកនិងឆ្លើយសំណួរនៅក្នុង «ទម្រង់ពាក្យស្នើសុំ»។ រួចហើយ អ្នកអាចដាក់ពាក្យស្នើសុំមិនឱ្យលើសពីថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៥ តាមរយៈមធ្យោបាយណាមួយខាងក្រោម៖

- បើមានអ៊ីម៉េល ផ្ញើមកអ៊ីម៉េល sormanak@cambodianlivingarts.org
- បើពុំមានអ៊ីម៉េល អាចផ្ញើតាមលេខតេលេក្រាម ០១០ ៩៤១ ២២៤
- ឬយកមកដាក់ផ្ទាល់នៅការិយាល័យអង្គការសិល្បៈខ្មែរអមតៈនៅ (ផ្ទះលេខ ១៣E ផ្លូវលេខ ៨៣០ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ)

ប្រសិនបើអ្នកមានសំណួរទាក់ទងនឹងកម្មវិធីឬការដាក់ពាក្យ អ្នកអាចទាក់ទងមកយើងខ្ញុំតាមរយៈ អ៊ីម៉េល sormanak@cambodianlivingarts.org ឬ តេលេក្រាមលេខ ០១០ ៩៤១ ២២៤។